00897689

D404/2/4.6

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អបជ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៣

ភាគីដាក់ឯកសារ: មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: បារាំង

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ហោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យពិនិត្យសម្រេចឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

**08-VU-2258 (D22/0039)**

---

<u>ដាក់ដោយ៖</u>

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក សំ សុគង់

មេធាវី Patrick BAUDOIN

មេធាវី Marie GUIRAUD

<u>ផ្ញើជូន៖</u>

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉ីយ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

<u>ចម្លងជូន៖</u>

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

## ១. ការរំលឹកអំពីនីតិវិធី

១. កាលពីថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ដើមបណ្តឹងរដ្ឋប្បវេណី **08-VU-2258 (D22/0039)** ត្រូវបានប្រកាសថាមិនអាចទទួលយកបាន តាមរយៈដីកា **(D404)** របស់សហចៅក្រមស៊ើបអង្កេត ដោយមូលហេតុដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនបានផ្តល់ភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ ។

២. កាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាខាងលើ ទៅអង្គបុរេជំនុំជម្រះ ដោយបានភ្ជាប់ទៅជាមួយនូវឯកសារអត្តសញ្ញាណមួយច្បាប់ **(D404/7/1** "បណ្តឹងឧទ្ធរណ៍ អ.ជ.ស.ដ ១១៩")។

៣. កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយ **(D404/2/4.3** ទំព័រ ៦) ដែលបញ្ជាក់អំពីភាពដែលមិនអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដោយមូលហេតុខ្វះនូវភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណ ពីព្រោះថា *"១២) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 08-VU-2258 (D22/0039) ។ អ្នកដាក់ពាក្យសុំបានលើកឡើងថា គាត់គឺជាជនរងគ្រោះផ្ទាល់នៃការជម្លៀសចេញពីទីក្រុងភ្នំពេញ នៅខែ មេសា ឆ្នាំ ១៩៧៥។ យោងតាមសហមេធាវី សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការប្រកាសថា ពាក្យសុំមិនអាចទទួលយកបានទេ ដោយហេតុថា គាត់មិនបានផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ។ ការបង្ហាញអត្តសញ្ញាណរបស់មនុស្សម្នាក់ គឺជាលក្ខខណ្ឌកំណត់ដែលចាំបាច់ដែលត្រូវមាននៅក្នុងបណ្តឹងរដ្ឋប្បវេណី មិនថាលក្ខខណ្ឌនេះត្រូវបានបញ្ជាក់ ឬមិនបានបញ្ជាក់នៅក្នុងវិធាននីតិវិធីនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានលើកឡើងដោយសហមេធាវី ចៅក្រមភាគច្រើនកត់សម្គាល់ឃើញថា នៅពេលដែលអ្នកដាក់ពាក្យសុំបានដាក់ពាក្យសុំរបស់ខ្លួន វិធាន ២៣ ស្ទួន(១)(ក) នៃវិធានផ្ទៃក្នុងដែលតម្រូវជាលក្ខខណ្ឌជាក់លាក់ នៃភាពអាចទទួលយកបានថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញអត្តសញ្ញាណឲ្យបានច្បាស់លាស់នោះ មិនទាន់ត្រូវបានអនុម័តនៅឡើយទេ។ យ៉ាងណាក៏ដោយ ពេលនោះទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះបានបញ្ចូលនូវផ្នែកទី ១១ ដែលមានចំណងជើងថា "តើឯកសារ*

*បញ្ជាក់អត្តសញ្ញាណខាងក្រោមណាមួយដែលអ្នកមាន? សូមបញ្ជាក់ជាលេខ" ដែលមានចម្លើយចំនួន ១០ ដែលក្នុងនោះចម្លើយមួយត្រូវបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំ គឺចម្លើយដែល សរសេរថា "គ្មាន"។ ១៣) ដោយគិតដល់កា:ទេស:ទាំងអស់នេះ សម្រាប់អ្នកដាក់ពាក្យសុំ វាមិនច្បាស់លាស់ទេថាការខកខាន មិនបានផ្តល់ភស្តុតាងបញ្ជាក់អត្តសញ្ញាណអាចធ្វើឱ្យពាក្យសុំមិនអាចទទួលយកបាន។ ហេតុដូច្នេះ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានព្យាយាមស្នើសុំសហមេធាវីម្តងទៀត ដាក់ឯកសារអត្តសញ្ញាណរបស់កូនក្តីខ្លួនមួយច្បាប់។ អង្គបុរេជំនុំជម្រះបានផ្ញើសំណើមួយថែម ទៀតជូនសហមេធាវី នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១។ ពាក្យសុំត្រូវបានបដិសេធចោល ពីព្រោះអង្គបុរេជំនុំជម្រះមិនបានទទួលចម្លើយតបណាមួយឡើយ"។*

៤. ដោយឡែក ភស្តុតាងនោះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងតាំងតែពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ដោយមានលេខឯកសារ **D404/7/1.2 (ERN 00611487)** ។

៥. មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដល់អង្គជំនុំជម្រះមេត្តាពិនិត្យឡើងវិញ លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសទទួលយកដើមបណ្តឹងរដ្ឋប្បវេណីនេះ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២។

## ២. ច្បាប់ដែលត្រូវអនុវត្ត

៦. ការសម្រេចមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណី 08-VU-2258 (D22/0039) កើតចេញមកពីកំហុសឆ្គងយ៉ាងជាក់ច្បាស់របស់អង្គជំនុំជម្រះ ទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ថាជាភាគីនៃរឿងក្តីដែរនោះ ដោយហេតុថា មូលហេតុតែមួយគត់នៃការសម្រេចពុំទទួលយកដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលស៊ើបសួរ ដោយសារពុំមានភស្តុតាងបញ្ជាក់អត្តសញ្ញាណ ត្រូវបានកែតម្រូវវិញតាមរយៈការដាក់ភស្តុតាងនោះក្នុង បណ្តឹងឧទ្ធរណ៍នោះ។

៧. សំណើសុំឱ្យធ្វើការសម្រេចឡើងវិញស្តីអំពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានទទួលយកជាច្រើនលើកច្រើនសាដោយអង្គជំនុំជម្រះ មិនថាសំណើសុំនោះធ្វើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្ប

វេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ឬត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះផ្ទាល់នោះទេ។

៨. នៅក្នុងករណីដែលអង្គជំនុំជម្រះមានកំហុសឆ្គងក្នុងការវាយតម្លៃលើអង្គហេតុ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្នើដល់អង្គជំនុំជម្រះមេត្តាទទួលស្គាល់ថា ភ័ស្តុតាងដែលពុំបានដាក់តាំងពីដំបូង ពោលគឺ ឯកសារអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងយ៉ាងត្រឹមត្រូវ តាំងពីពេលដែលមានសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ម៉្លេះ និងសូមស្នើដល់អង្គជំនុំជម្រះមេត្តាទទួលស្គាល់អំពីកិច្ចប្រឹងប្រែងដ៏ធំធេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ឯកសារចាំបាច់នានាសម្រាប់ឱ្យមានការទទួលស្គាល់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

**ហេតុដូច្នេះ**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដល់អង្គជំនុំជម្រះមេត្តា៖**

- សម្រេចតាមសំណើសុំឱ្យមានការពិនិត្យសម្រេចឡើងវិញនេះ។
- ទទួលស្គាល់ថា ភ័ស្តុតាងបញ្ជាក់អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានសម្រេចថាពុំត្រូវបានដាក់នោះ ជាក់ស្តែងត្រូវបានដាក់យ៉ាងត្រឹមត្រូវកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០។
- ដូច្នេះ ប្រកាសទទួលយកអ្នកដាក់ពាក្យសុំ **08-VU-2258 (D22/0039)** ថាជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

**Marie GUIRAUD**

ស៊ិ - សំណាង